

# របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ

# ផែនការយុទ្ធសាស្ត្រ ២០១៦ - ២០២០

## នៅសណ្ឋាគារ ហ្វូលីដេ, ខេត្តបាត់ដំបង

ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០១៨

(បានរៀបចំឡើងដោយមានការចូលរួមពីសមាជិកចំនួន ៥២រូប)

## អង្គការប្រតិបត្តិការកុមារកម្ពុជា
(ប្រ.ក.ក.)

# របាយការណ៍វាយតម្លៃពាក់កណ្ដាលអាណត្តិ
# ផែនការយុទ្ធសាស្ត្រ ២០១៦-២០១២០

## I- អារម្ភកថារបស់ក្រុមប្រឹក្សានាយក

ក្រោយឆ្នាំ ១៩៩៣ ប្រទេសកម្ពុជាយើងទទួលបាននូវការស្ដារមុខមាត់ថ្មីឡើងវិញបន្តិចម្ដងៗជាលំដាប់ ដែលក្នុងនោះ មានម្ចាស់ជំនួយអន្តរជាតិជាច្រើន បានផ្ដល់នូវជំនួយផ្សេងៗដ៏ច្រើនសន្ធឹកសន្ធាប់ក្នុងគោលបំណងចូលរួមស្ដារ និង អភិវឌ្ឍន៍ ប្រទេសកម្ពុជារបស់យើង ។ ទន្ទឹមនេះ ក៏បានជម្រុញឲ្យអង្គការប្រតិបត្តិការកុមារកម្ពុជា (OEC) មានឱកាសចូលរួមក្នុងការ បំពេញបេសកកម្មរបស់ខ្លួន ដោយបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៦ រហូតទល់ពេលបច្ចុប្បន្ន ។ រយៈពេលកន្លងមកនេះ អង្គការប្រតិបត្តិការកុមារកម្ពុជា បានបញ្ចប់ផែនការយុទ្ធសាស្ត្រលើកដំបូងរបស់ខ្លួន ឆ្នាំ ២០១១-២០១៥ និង បច្ចុប្បន្នបាន និង កំពុងរៀបចំធ្វើការវាយតម្លៃពាក់កណ្ដាលអាណត្តិផែនការយុទ្ធសាស្ត្រជាលើកទី២ ឆ្នាំ២០១៦-២០២០ នាឱកាសនេះផងដែរ។ ក្នុងនាមគណៈកម្មការវាយតម្លៃ និង ជំនួសមុខក្រុមប្រឹក្សានាយកនៃអង្គការប្រតិបត្តិការកុមារកម្ពុជា ខ្ញុំមានបីតិសោមនស្សរីករាយ ក្រៃលែង និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគ្រប់ស្ថាប័ន ក៏ដូចជា ឯកឧត្តម, លោកជំទាវ, លោក/លោកស្រី ជាសមាជិកនៃអង្គពិធីទាំងអស់ ដែលបានឆ្លៀតឱកាស និង លះបង់ពេលវេលាដ៏មានតម្លៃ ដើម្បីចូលរួមចែករំលែកនូវបទ-ពិសោធន៍, វិធីសាស្ត្រសំខាន់ៗ ដើម្បីជម្រុញឲ្យដំណើរការនៃការរៀបចំការវាយតម្លៃរបស់យើងនាពេលនេះ ទទួលបានជោគជ័យ និង ផ្លែផ្កាដ៏មហិមាគួរឲ្យកត់សម្គាល់ ។ ទន្ទឹមនឹងនេះដែរ យើងខ្ញុំក៏សូមថ្លែងអំណរគុណ ជាពិសេស ចំពោះម្ចាស់ជំនួយទាំងអស់ រួមមាន៖ BICE, Oak, MISEREOR, KINDER-MISSIONSWERK, Schmitz Stiftungen, Save the Children/Aide et Action, IKEA Foundation and USAID/Save the Children ដែលតែង ឧបត្ថម្ភមូលនីធិ ដើម្បីឲ្យអង្គការយើងមានឱកាស ក៏ដូចជាធនធានក្នុងកិច្ចអន្តរាគមន៍ដើម្បីជួយដល់ក្រុមគោលដៅរបស់យើង ជាពិសេសគឺកុមារដែលរស់នៅតាមតំបន់ដាច់ស្រយាល, កុមារកំព្រា, កុមារស្ថិតក្នុងគ្រួសាររងគ្រោះដោយមេរោគ/ជម្ងឺអេដស៍, កុមារពិការ, កុមារក្រៅសាលា, កុមាររងាយរងគ្រោះ និង កុមារជនជាតិដើមភាគតិច នៅក្នុងប្រទេសកម្ពុជាទាំងមូល តាមរយៈ ការកសាងផែនការយុទ្ធសាស្ត្រ ឆ្នាំ២០១៦-២០២០ ។ យើងខ្ញុំមានក្ដីសោមនស្សរំភើបរីករាយក្រៃលែង ចំពោះវត្តមានចូល រួមយ៉ាងជិតស្និទ្ធពីសំណាក់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ តាំងពីថ្នាក់ខេត្ត, ស្រុក និង ឃុំ ព្រមទាំងសមាជិកសហគមន៍ ដែលបាន ជួយជ្រោមជ្រែងដល់ក្រុមវាយតម្លៃរបស់យើងខ្ញុំ អនុវត្តការងារប្រកបដោយភាពរលូនបំផុត ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណផង ដែរ ចំពោះអង្គការក្រៅរដ្ឋាភិបាល រួមទាំងអង្គការសង្គមស៊ីវិលដទៃទៀត ដែលជាចំណែកមួយដ៏មានសារៈសំខាន់ក្នុងការផ្ដល់ ព័ត៌មាន ព្រមទាំងឯកសារនានា ដើម្បីជួយជម្រុញឲ្យកិច្ចការរបស់យើងទទួលបានជោគជ័យ ។ ស្មារតីខិតខំប្រឹងប្រែងរបស់ពួកគេ ក្នុងការចូលរួមធ្វើការវាយតម្លៃ ព្រមទាំងការឆ្លុះបញ្ចាំងពីបទពិសោធន៍ល្អៗទាំងឡាយ បានជួយកែលម្អដល់ការត្រួតពិនិត្យការ វាយតម្លៃរបស់យើង ឲ្យកាន់តែមានភាពប្រសើរឡើងថែមទៀត។ ព្រមជាមួយគ្នានេះដែរ យើងក៏សូមអរគុណយ៉ាងជ្រាលជ្រៅ ចំពោះបុគ្គលិក OEC ទាំងអស់ ដែលជានិច្ចជាកាលតែងប្រកាន់ខ្ជាប់នូវជំហរអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ក្នុងន័យ ស្ថាបនា និង ពុំមានភាពលំអៀង ជារៀងដរាបមក ។

## II- មាតិកា

**ចំណងជើងអត្ថបទ** **លេខទំព័រ**


១. អារម្ភកថារបស់ក្រុមប្រឹក្សានាយក ....................................................................................... ២
២. មាតិកា ....................................................................................................................... ៣
៣. សេចក្តីសង្ខេប ................................................................................................................ ៤
៤. សេចក្តីផ្តើម ................................................................................................................... ៧
   ៤.១. សាវតា ...................................................................................................................... ៧
   ៤.២. គោលដៅរួមនៃការត្រួតពិនិត្យការវាយតម្លៃពាក់កណ្តាលអាណត្តិផែនការយុទ្ធសាស្រ្ត................ ៧
   ៤.៣. គោលបំណងនៃការត្រួតពិនិត្យការវាយតម្លៃពាក់កណ្តាលអាណត្តិផែនការយុទ្ធសាស្រ្ត ............. ៨
   ៤.៤. សនិទានីយភាពនៃការត្រួតពិនិត្យការវាយតម្លៃពាក់កណ្តាលអាណត្តិផែនការយុទ្ធសាស្រ្ត .......... ៩
   ៤.៥. ការងារគ្រប់គ្រងនិងសម្របសម្រួលការត្រួតពិនិត្យការវាយតម្លៃពាក់កណ្តាលអាណត្តិ
   ផែនការយុទ្ធសាស្រ្ត ....................................................................................................... ៩
   ៤.៦. វិន័យរបស់សមាជិកគណៈកម្មការវាយតម្លៃ ..................................................................... ១០
៥. យុទ្ធវិធី .................................................................................................................... ១០
   ៥.១. វិធីសាស្រ្ត ............................................................................................................. ១០
   ៥.២. ការវិភាគលើរបកគំហើញនិងសេចក្តីសន្និដ្ឋាន .................................................................. ១១
៦. សេចក្តីសន្និដ្ឋាន ........................................................................................................... ១៥
៧. ដំហានបញ្ចប់ ................................................................................................................. ១៥

## III- សេចក្តីសង្ខេប

អង្គការប្រតិបត្តិការកុមារកម្ពុជា (OEC) បានបន្តរៀបចំនូវផែនការយុទ្ធសាស្ត្ររបស់ខ្លួន ឆ្នាំ២០១៦-២០២០ ដោយរក្សាទុកនូវកម្មវិធីចំនួន៣ ដដែល ក្នុងនោះមាន៖

១. កម្មវិធីអភិវឌ្ឍសិទ្ធិកុមារ (CRDP)

២. កម្មវិធីលើកកម្ពស់សិទ្ធិជនពិការ និងជនរងគ្រោះដោយសារមីន (PWD/LVSP)

៣. កម្មវិធីលើកកម្ពស់សិទ្ធិស្ត្រីនៅជនបទ (RWEP) ។

នៅក្នុងដំណាក់កាលចាប់ផ្តើមនៃផែនការយុទ្ធសាស្ត្រ ឆ្នាំ២០១៦ កម្មវិធីអភិវឌ្ឍសិទ្ធិកុមារ មានគម្រោងសរុបទាំងអស់ចំនួន ៩ គឺ៖

១. ការទប់ស្កាត់ការរំលោភបំពានលើកុមារ ដែលជាផ្នែកទាំងមូលរបស់កម្មវិធី “ ភាពញញឹមនៃកុមារកម្ពុជា ”, គម្រោងនេះទទួលបានការឧបត្ថម្ភអំពី BICE & OAK Foundation ។

២. ភាពញញឹមនៃកុមារកម្ពុជា, ទទួលបានការឧបត្ថម្ភអំពី MISEREOR,

៣. ភាពញញឹមនៃកុមារកម្ពុជា, ទទួលបានការឧបត្ថម្ភអំពី KINDERMISSIONSWERK,

៤. ការលើកកម្ពស់ការអប់រំ និងការថែទាំសុខភាពកុមារកំព្រា/ក្រីក្រ និង កុមារក្នុងគ្រួសាររងគ្រោះដោយមេរោគអេដស៍/ជម្ងឺអេដស៍, ទទួលបានការឧបត្ថម្ភអំពី KINDERMISSIONSWERK,

៥. ការលើកកម្ពស់ការអប់រំ និងការថែទាំសុខភាពកុមារកំព្រា/ក្រីក្រ និង កុមារក្នុងគ្រួសាររងគ្រោះដោយមេរោគ/ជម្ងឺអេដស៍, ទទួលបានការឧបត្ថម្ភអំពី SCHMITZ STIFTUNGEN,

៦. ការលើកកម្ពស់សិទ្ធិមនុស្ស និង ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព, ទទួលបានការឧបត្ថម្ភ អំពី SCHMITZ STIFTUNGEN,

៧. កម្មវិធីអប់រំ និង កិច្ចសង្គ្រោះបន្ទាន់សម្រាប់កុមារក្នុងគ្រួសាររងគ្រោះដោយមេរោគ/ជម្ងឺអេដស៍, ទទួលបានការឧបត្ថម្ភអំពី KINDERMISSIONSWERK,

៨. ការអប់រំសម្រាប់ទាំងអស់គ្នា “ វិធីសាស្ត្ររួមបញ្ចូលគ្នានៃសមាគមក្នុងប្រទេសកម្ពុជា ដើម្បីកុមារក្រៅសាលា ”, ទទួលបានការគាំទ្រថវិកាអំពី Aid et Action តាមរយៈ Save the Children,

៩. ការជានាការអនុវត្តសិទ្ធិកុមារពិការ ទទួលបានការគាំទ្រពីមូលនីធិ IKEA តាមរយៈ Save the Children ។

ក្នុងកម្លុងពេលនៃការចាប់ផ្តើមផែនការយុទ្ធសាស្ត្រ កម្មវិធីអភិវឌ្ឍសិទ្ធិកុមារ (CRDP) គឺត្រូវបានគេមើលឃើញថា មានគោលបំណងសំខាន់ៗចំនួន ៣ ៖

ក) ការទប់ស្កាត់ការរំលោភបំពានគ្រប់រូបភាពលើកុមារ ជាពិសេសគឺ ការកេងប្រវ័ញ្ចលើកុមារ តាមរយៈការពង្រឹងបណ្តាញកិច្ចការពារកុមារ (មានគម្រោងចំនួន ៣) ដែលក្នុងនោះ គឺផ្តល់សិទ្ធិអំណាចដល់សមាគមមាតាបិតា និង ក្លឹបកុមារដែលមានប្រភពធនធានចេញពីការរៀបចំនូវថ្នាក់អប់រំក្រៅប្រព័ន្ធ និង កន្លែងកុមារមេត្រី ដែលបានបង្កើតឡើងនៅតាមបណ្តាឃុំនានាក្នុងស្រុកព្រៃនុប និង ស្រុកកំពង់សីលា, ខេត្តព្រះសីហនុ ក្រោមជំនួយឧបត្ថម្ភអំពី Bureau International Catholique de l'Enfance (BICE), Oak Foundation, MISEREOR and KINDERMISSIONSWERK ។ គម្រោងទាំងនេះ មានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត, គណៈកម្មការឃុំទទួលបន្ទុកកិច្ចការនារី និងកុមារ, គណៈកម្មការការពារកុមារស្រុក, ប៉ុស្តិ៍នគរបាលរដ្ឋបាល, ADHOC, LICADHO, APLE, HAGAR, World Hope and M'LOP TAPANG ដើម្បីផ្តល់កិច្ចអន្តរាគមន៍ និង ជួយសង្គ្រោះទាន់ពេលវេលាចំពោះសកម្មភាពរំលោភបំពាន ឬបទល្មើសផ្លូវភេទផ្សេងៗលើកុមារ ។

ខ) ការអប់រំសម្រាប់ទាំងអស់គ្នា និងការអប់រំបរិយាប័ន្ន (មានគម្រោងចំនួន ២) ដែលគោលដៅសំខាន់ គឺសំដៅលើកកម្ពស់លទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌ សម្រាប់កុមារងាយរងគ្រោះ, កុមារក្រៅសាលា និងកុមារពិការ ។ គម្រោងនេះ ទទួលបានការគាំទ្រថវិកាអំពី Aide et Action និង IKEA Foundation តាមរយៈអង្គការ Save the Children ។ តំបន់ប្រតិបត្តិការរបស់គម្រោង មានចំនួន ៩ ខេត្ត គឺ៖ ខេត្តកំពង់ចាម, ត្បូងឃ្មុំ, កំពង់ឆ្នាំង, ព្រះវិហារ, កោះកុង,

ស្ទឹងត្រែង, ពោធិ៍សាត់, ព្រៃវែង និង ក្រចេះ ។ Save the Children/Aide et Action បានទទួលជោគជ័យក្នុងការកៀងគរអ្នកចូលរួមពីគ្រប់សមាសភាព រួមមាន៖ មន្ត្រីអប់រំថ្នាក់ខេត្ត, ថ្នាក់ស្រុក, នាយកសាលា, គ្រូបង្រៀន, គណៈកម្មការទ្រទ្រង់សាលា (SSC), អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់, សមាជិកក្រុមប្រឹក្សាឃុំ, គកនក, បានចូលរួមផ្សាភ្ជាប់ជាមួយនឹងសកម្មភាពគម្រោងក្នុងប្រមូលកុមារលើគ្រប់ស្ថានភាពទាំងអស់ ឲ្យចូលរៀននៅក្នុងសាលារដ្ឋ ។ ទន្ទឹមនេះ គម្រោងបានបង្កើតគណៈកម្មការផ្តល់អាហារូបករណ៍ ដើម្បីធ្វើការជ្រើសរើសកុមារដែលមានលក្ខណៈវិនិច្ឆ័យក្នុងការទទួលបាននូវអាហារូបករណ៍, មធ្យោបាយធ្វើដំណើរ, សម្ភារសិក្សា និង ស្បៀងអាហារថែមទៀតផង ។ ដើម្បីជាការលើកកម្ពស់គុណភាពអប់រំ គម្រោងបានធ្វើការបណ្តុះសមត្ថភាពដល់គ្រូបង្រៀន តាមរយៈការរៀបចំជា វគ្គសិក្ខាសាលា, វគ្គបណ្តុះបណ្តាលផ្សេងៗ ដោយមានការចូលរួមសហការជាមួយស្ថាប័នអប់រំ លើប្រធានបទស្តីអំពី ៖ ដំណាក់កាលអភិវឌ្ឍកុមារ, វិធីសាស្ត្ររៀន និងបង្រៀន, ជំនាញក្នុងការគ្រប់គ្រងថ្នាក់រៀន, វិធីសាស្ត្រវាយតម្លៃលទ្ធផលសិក្សា រួមទាំងការរៀបចំផែនទីសិក្សា និង ផែនការអភិវឌ្ឍន៍ជាដើម ។

គ) ការលើកកម្ពស់ការអប់រំ និងការថែទាំសុខភាពកុមារកំព្រា/ក្រីក្រ និង កុមារក្នុងគ្រួសាររងគ្រោះដោយមេរោគអេដស៍/ជម្ងឺអេដស៍ មានគោលដៅពង្រឹងសិទ្ធិទទួលបានការសិក្សាប្រកបដោយគុណភាព, ការលប់បំបាត់ការរើសអើងនៅក្នុងវិស័យអប់រំ និង ការលើកកម្ពស់សេរីភាពនៃកាលឱកាស ដោយបានផ្តល់ជាអាហារូបករណ៍ដល់កុមារក្រីក្រ, កុមារកំព្រា និងកុមារស្ថិតក្នុងគ្រួសារផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ ។ ទន្ទឹមនេះ គម្រោងបានផ្តល់ជា ពូជសត្វ, ពូជបន្លែ ឬជនជានសម្ភារ ដល់ឪពុក/ម្តាយរបស់ពួកគេ ដើម្បីមានលទ្ធភាពក្នុងការអនុវត្តសកម្មភាពបង្កើនប្រាក់ចំណូលនៅក្នុងគ្រួសារ និង ជួយទំនុកបម្រុងលើការសិក្សារបស់កូនៗថែមទៀតផង ។ KINDERMISSIONSWERK បានឧបត្ថម្ភលើគម្រោងចំនួន ២, គម្រោងទី១៖ អនុវត្តនៅក្នុងស្រុកសង្កែ ដែលមានឃុំចំនួន ៣ គឺ៖ ឃុំរកា, តាប៉ុន, រាំងកេសី (សរុបមាន ១៦ភូមិ) ។ គម្រោងទី២៖ បានជួយដល់កុមារស្ថិតក្នុងគ្រួសារផ្ទុកមេរោគ/ជម្ងឺអេដស៍ ចំនួន ១០៧នាក់ និង ក្រុមគ្រួសារដែលបានឆ្លងមេរោគ/ជម្ងឺអេដស៍ ចំនួន ៥៨ គ្រួសារ ស្ថិតនៅក្នុងភូមិចំនួន ៦ របស់ឃុំរកា, ស្រុកសង្កែ, ខេត្តបាត់ដំបង ។ SCHMITZ STIFTUNGEN បានឧបត្ថម្ភគម្រោងចំនួន ២, គម្រោងទី១៖ អនុវត្តនៅក្នុងឃុំចំនួន៣ របស់ស្រុកឯកភ្នំ រួមមាន៖ ឃុំព្រែកខ្ពប, ៣មឯក និង ព្រែកនរិន្ទ, សរុបភូមិចំនួន ១៦ភូមិ។ គម្រោងបានគាំទ្រជាសម្ភារសិក្សាប្រចាំឆ្នាំ ដល់កុមារគោលដៅចំនួន ៦០នាក់ ទៅតាមកម្រិតសិក្សា និងឧបត្ថម្ភថ្លៃរៀនមុខវិជ្ជាបំប៉នដល់សិស្សដែលរៀនខ្សោយចំនួន ២១នាក់។ ទន្ទឹមនេះ គម្រោងបានឧបត្ថម្ភដល់សមាជិកគ្រួសាររបស់ពួកគេ ដើម្បីមានលទ្ធភាពក្នុងការអនុវត្តនូវសកម្មភាពរកប្រាក់ចំណូលផងដែរ ។ គម្រោងទី២៖ មានឈ្មោះថា “ ការលើកកម្ពស់សិទ្ធិមនុស្ស និង ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ” ដែលបាន និងកំពុងប្រតិបត្តិការនៅក្នុងឃុំតាម៉ឺន និង ឃុំតាពូង, ស្រុកថ្មគោល, ខេត្តបាត់ដំបង ។ គោលបំណងសំខាន់របស់គម្រោង គឺសំដៅជួយឧបត្ថម្ភដល់កុមារដែលមានឪពុកម្តាយធ្វើចំណាកស្រុក ដោយបានផ្តល់ឱកាសដល់កូនៗរបស់ពួកគេទទួលបាននូវបរិយាកាសសិក្សាល្អ ។ ក្នុងនោះដែរ គម្រោងនៅបានជួយគាំទ្រ ជាពូជសត្វ ឬ ពូជដំណាំផ្សេងៗ ដល់សមាជិកគ្រួសារ ចំនួន ១០គ្រួសារ ដើម្បីឲ្យពួកគាត់មានលទ្ធភាព ក្នុងសកម្មភាពបង្កើនប្រាក់ចំណូល និង កែប្រែជីវភាពរស់នៅឲ្យមានភាពល្អប្រសើរឡើងវិញ ។

មកដល់ពាក់កណ្តាលឆ្នាំ ២០១៨នេះ អង្គការប្រតិបត្តិការកុមារកម្ពុជា នៅសល់គម្រោងចំនួន ៦ប៉ុណ្ណោះ ក្នុងនោះមាន៖ ១. គម្រោង៖ “ ភាពញញឹមនៃកុមារកម្ពុជា ” ដែលឧបត្ថម្ភដោយ MISEREOR, ២. គម្រោងៈ “ ភាពញញឹមនៃកុមារកម្ពុជា ” ឧបត្ថម្ភដោយ BICE/OAK Foundation & KINDERMISSIONSWERK, ៣. គម្រោងៈ “ ការលើកកម្ពស់ការអប់រំ និង ការថែទាំសុខភាពកុមារកំព្រា/ក្រីក្រ និង កុមារក្នុងគ្រួសាររងគ្រោះដោយមេរោគអេដស៍/ជម្ងឺអេដស៍ ” ឧបត្ថម្ភដោយSchmitz Stiftungen, ៤. គម្រោងៈ “ ការលើកកម្ពស់ការអប់រំ និង ការថែទាំសុខភាពកុមារកំព្រា/ក្រីក្រ និងកុមារក្នុងគ្រួសាររងគ្រោះដោយមេរោគអេដស៍/ជម្ងឺអេដស៍ ” ឧបត្ថម្ភដោយ KINDERMISSIONSWERK, ៥. គម្រោងៈ “កម្មវិធីអប់រំ និង កិច្ចសង្គ្រោះបន្ទាន់សម្រាប់កុមារក្នុងគ្រួសាររងគ្រោះដោយមេរោគអេដស៍/ជម្ងឺអេដស៍ ” ដែលឧបត្ថម្ភដោយ KINDERMISSIONSWERK, ៦. គម្រោងៈ “ ការធានាសិទ្ធិកុមារជាប់ពិការភាព ” ឧបត្ថម្ភដោយ មូលនីធិ IKEA ។

រហូតដល់ការវាយតម្លៃពាក់កណ្តាលអាណត្តិនេះ គឺនៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១៨ នេះ, OEC បានសម្រេចយុទ្ធសាស្ត្រចំនួន ៣ នៅក្នុងកម្មវិធីអភិវឌ្ឍន៍សិទ្ធិកុមារ (CRDP) “ក”, “ខ” និង “គ” ខណៈដែលសកម្មភាពចំនួន ៣ នៃយុទ្ធសាស្ត្រ “ឃ” ពាក់ព័ន្ធទៅនឹងវិធីសាស្ត្រនៃការធ្វើសមាហរណកម្មសិទ្ធិមនុស្សនៅក្នុងមេរៀនប្រចាំថ្ងៃ គឺយើងនៅពុំទាន់បានអនុវត្តនៅឡើយ ។ អង្គការប្រតិបត្តិការកុមារកម្ពុជា គួរខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការធ្វើឲ្យសម្រេចនូវយុទ្ធសាស្ត្រ “ឃ” ដើម្បី

ឆ្លើយតបទៅនឹងកម្មវិធីកិតពលោកដើម្បីការអប់រំសិទ្ធិមនុស្ស (២០០៥-២០០៩) និង ដើម្បីអភិវឌ្ឍបុគ្គលិកលក្ខណៈ, ទេព្យកោសល្យ ព្រមទាំងសមត្ថភាពផ្ទាល់ខ្លួនរបស់កុមារឲ្យបានពេញលេញបរិបូណ៌ អនុលោមតាមមាត្រា២៩ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

កម្មវិធីលើកកម្ពស់សិទ្ធិជនពិការ និងជនរងគ្រោះដោយសារមីន (PWD/LVSP) យើងមានផែនការស្នើសុំទៅម្ចាស់ជំនួយ ដើម្បីជួយគាំទ្រដល់គម្រោង ការលើកកម្ពស់ជីវភាពជនក្រីក្រ ដែលមានចំនួន ២០% (គោរពតាមស្មារតីនៃ SDG1), ៥០% ជនពិការគ្រប់ប្រភេទ និង ៣០% ជនដែលរងគ្រោះដោយសារមីន ហើយដែលយើងបានកំណត់ជ្រើសរើសធ្លាស់គ្រួសារគោក្នុងមួយឆ្នាំគឺមានចំនួន ៣០០គ្រួសារ នៅតាមបណ្តាខេត្តចំនួន ៥ ដែលមានព្រំប្រទល់ជាប់នឹងប្រទេសថៃ និង ជាតំបន់ដែលធ្លាប់រងផលប៉ះពាល់ដោយជម្លោះប្រដាប់អាវុធដ៏រ៉ាំរ៉ៃបំផុត (ខេត្តបាត់ដំបង, ប៉ៃលិន, បន្ទាយមានជ័យ, ឧត្តរមានជ័យ និងខេត្តព្រះវិហារ) ។ នៅពេលចាប់ផ្តើមពាក់កណ្តាលផែនការយុទ្ធសាស្ត្រ ២០១៦-២០២០, ផែនការនេះពុំទាន់បានសម្រេចលទ្ធផលនៅឡើយ ដោយសារតែពុំទាន់ទទួលបានការព្រមព្រៀងអំពីម្ចាស់ជំនួយ ។ OEC បានដាក់បញ្ចូលសិទ្ធិជនពិការ និង សិទ្ធិកុមារពិការ ទៅក្នុងគម្រោងអប់រំបរិយាប័ន្ន, កិច្ចការពារកុមារ ដើម្បីទប់ស្កាត់ទៅនឹងការរំលោភបំពានលើគ្រប់រូបភាព តាមរយៈសមាគមមាតាបិតា និងសកម្មភាពក្លឹបកុមារ ដែលមានការឧបត្ថម្ភគាំទ្រដោយ BICE/Oak Foundation និង MISEREOR និងកម្មវិធីអប់រំបរិយាប័ន្ន ដែលមានការឧបត្ថម្ភអំពី Aide et Action និង IKEA តាមរយៈ Save the Children ។ ទន្ទឹមនេះដែរ OEC ធ្លាប់បានអនុវត្តយ៉ាងសកម្មនូវកម្មវិធីលើកកម្ពស់សិទ្ធិជនពិការ ក្រោមការឧបត្ថម្ភថវិកាអំពី Adopt-A-Minefield ចាប់ តាំងពីឆ្នាំ ២០០៣ រហូតដល់ឆ្នាំ ២០១៥ ។

ផ្អែកតាមលទ្ធផលជំរឿនស្ថិតិជនពិការ ឆ្នាំ២០០៨ បានបង្ហាញឲ្យឃើញថា នៅក្នុងខេត្តបាត់ដំបងមានជនពិការសរុបចំនួន ១០,២៦% ក្នុងនោះមាន ០,៧០% រស់នៅតាមតំបន់ជាយក្រុងឬទីប្រជុំជន និងមាន ៩,៧៦% រស់នៅតាមជនបទ ។ ហេតុនេះ OEC គួរព្យាយាមទំនាក់ទំនងជាមួយបណ្តាអង្គការនានា និង ស្វែងរកប្រភពថវិកា ដើម្បីគាំទ្រដល់ជនពិការក្រីក្រទាំងអស់នោះ ។

កម្មវិធីលើកកម្ពស់សិទ្ធិស្ត្រីនៅជនបទ មានយុទ្ធសាស្ត្រចំនួន ៤គឺ ៖
១. សិទ្ធិក្នុងការអប់រំ,
២. សមភាពយែនឌ័រ,
៣. សុខភាពស្ត្រីជនបទ,
៤. សកម្មភាពរកប្រាក់ចំណូល

នៅពេលចាប់ផ្តើមពាក់កណ្តាលផែនការយុទ្ធសាស្ត្រ, កម្មវិធី RWEP មានគម្រោងតែមួយប៉ុណ្ណោះ គឺគម្រោងនូរីស ។ គម្រោងនេះទទួលបានការឧបត្ថម្ភអំពី USAID តាមរយៈអង្គការ Save the Children ដែលបានចាប់ផ្តើមសកម្មភាពនៅក្នុងឆ្នាំ២០១៤ ។ គោលបំណងសំខាន់របស់គម្រោង គឺផ្តោតលើការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ និង សុខុមាលភាពស្ត្រីនិងកុមារនៅតាមសហគមន៍ជនបទ, ការរួមបញ្ចូលកម្មវិធីអាហារូបត្ថម្ភ, ទឹកស្អាត, សុខភាព/អនាម័យ និង កសិកម្ម ។ គម្រោងនេះបានអនុវត្តនៅក្នុងស្រុកចំនួន ៩ របស់ ខេត្តបាត់ដំបង គឺ៖ ស្រុកសង្កែ, ថ្មគោល, មោងឬស្សី, គាស់ក្រឡ, រុក្ខគីរី, រតនមណ្ឌល, សំឡូត, បវេល និង កំរៀង ។ មកទល់បច្ចុប្បន្ន យើងមានប្រជាពលរដ្ឋគោលដៅដែលស្ថិតនៅតាមបណ្តាភូមិទាំង ១២៤ សរុបចំនួន ៦,២៩៧នាក់ បានចូលរួមរាល់សកម្មភាពរបស់គម្រោង និង មានគ្រួសារចំនួន១,១៧១ បានរៀបចំធ្វើបង្គន់អនាម័យ ។ បច្ចុប្បន្ន គម្រោងនូរីស គឺបាន និងកំពុងបន្តអនុវត្តនូវសកម្មភាពរបស់ខ្លួនយ៉ាងសកម្ម ។ សកម្មភាពដូចបានពណ៌នាខាងដើម បានបម្រើឲ្យយុទ្ធសាស្ត្រទី ៣ តែមួយប៉ុណ្ណោះ គឺការលើកកម្ពស់សុខភាពស្ត្រីនៅជនបទ ។ ចំណែកយុទ្ធសាស្ត្រផ្សេងទៀត គឺយុទ្ធសាស្ត្រទី១, ទី២ និង ទី៤ នៅពុំទាន់បានសម្រេចនៅឡើយទេ ។

អង្គការប្រតិបត្តិការកុមារកម្ពុជា គួរខិតខំប្រឹងប្រែងដើម្បីបំពេញឲ្យបានតាមតម្រូវការរបស់ CEDAW នៅក្នុងមាត្រា១៤/២ និង SDG5 ដែលបានចែងថា ត្រូវធ្វើឲ្យសម្រេចនូវសមភាពយេនឌ័រ ព្រមទាំងផ្តល់សិទ្ធិអំណាចដល់ស្ត្រី និង កុមារីគ្រប់ៗរូបដែលយើងបានដាក់បញ្ចូលនៅក្នុងយុទ្ធសាស្ត្រទី “១”, “២” និង “៤” នៃកម្មវិធី លើកកម្ពស់សិទ្ធិស្ត្រីនៅជនបទ ។

## IV- សេចក្តីផ្តើម

### 1. ប្រវត្តិ/សាវតា

អង្គការប្រតិបត្តិការកុមារកម្ពុជា បានបង្កើតឡើងនៅថ្ងៃទី ១ ខែមីនា ឆ្នាំ១៩៩៦ និង បានទទួលស្គាល់ជាផ្លូវការពីក្រសួងមហាផ្ទៃ ដែលក្នុងពេលនោះមានឈ្មោះថា៖ **"អង្គការប្រតិបត្តិការកុមារខេត្តបាត់ដំបង"** ។ នៅពេលចាប់ផ្តើមសកម្មភាពដំបូង គឺបានជួយដល់ឪពុកម្តាយកុមារដែលរងគ្រោះដោយសារមីន និង កុមារដែលមានជម្ងឺ សម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យខេត្តបាត់ដំបង ស្ថិតក្រោមជំនួយឧបត្ថម្ភអំពីអង្គការអន្តរជាតិ រួមជាមួយនឹងមូលនិធិមនុស្សធម៌ពីក្រៅប្រទេស ។ អង្គការប្រតិបត្តិការកុមារខេត្តបាត់ដំបង បានពង្រីកសកម្មភាពរបស់ខ្លួនដើម្បីជួយដល់កុមារកំព្រានៃគ្រួសាររងគ្រោះដោយជម្ងឺអេដស៍កុមារពិការ , កុមាររស់នៅតាម ,និងកុមារស្ថិតក្នុងគ្រួសារក្រីក្រតំបន់ជួបការលំបាក ,ជម្រុញលើកទឹកចិត្តដល់កុមារ យុវជនក្រីក្រ ដោយការផ្តួចផ្តើមបង្កើតឲ្យមានជាថ្នាក់រៀន ព្រមទាំងរៀបចំគ្រូកិច្ចសន្យា ដោយមានការចូលរួមសហការពីសហគមន៍ សំដៅអភិវឌ្ឍន៍ការអប់រំ សិទ្ធិកុមារ និង ការថែទាំសុខភាពបឋមនៅតាមតំបន់ដាច់ស្រយាល ។ ការគាំទ្រលើសកម្មភាពផ្សេងទៀត នោះ គឺអង្គការប្រតិបត្តិការកុមារខេត្តបាត់ដំបងយើង បានធ្វើការពង្រីកសកម្មភាពរបស់ខ្លួននៅតាមបណ្តាខេត្តចំនួន ៥ ស្ថិតនៅប៉ែកពាយព្យនៃប្រទេសកម្ពុជា ។ ការវិវត្តន៍ប្រកបដោយផ្លែផ្កានៃសកម្មភាពអស់ទាំងនេះ បានជម្រុញឲ្យយើងសម្រេចប្តូរឈ្មោះពី អង្គការប្រតិបត្តិការកុមារខេត្តបាត់ដំបង មកជា « **អង្គការប្រតិបត្តិការកុមារកម្ពុជា** » វិញ ដោយមានលិខិតទទួលស្គាល់ពី ក្រសួងមហាផ្ទៃ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៦ ។ ចាប់ពីឆ្នាំ ២០១១ មក អង្គការប្រតិបត្តិការកុមារកម្ពុជា ក៏បានរៀបចំបង្កើតនូវផែនការយុទ្ធសាស្ត្ររបស់ខ្លួន ឆ្នាំ២០១១-២០១៥ ដោយបានរួមបញ្ចូលគម្រោងទាំងអស់របស់ OEC ទៅក្នុងកម្មវិធីសំខាន់ៗ ចំនួន ៣ ដែលមានការគ្រប់គ្រង និងសម្របសម្រួលដោយឡែកៗពីគ្នា ទៅតាមគោលដៅ និង លទ្ធផល ឆ្ពោះទៅកាន់គន្លងទស្សនៈវិស័យរបស់អង្គការ។ កម្មវិធីអភិវឌ្ឍន៍សិទ្ធិកុមារ (CRDP) ដែលជាការលើកកម្ពស់សិទ្ធនិងទំនួលខុសត្រូវរបស់កុមារមាតាបិ ,តាគ្រូបង្រៀន , និង ប្រជាពលរដ្ឋក្នុងការទទួលស្គាល់នូវការគោរព និងកិច្ចសហប្រតិបត្តិការរវាងសាលារៀន និងសហគមន៍ជុំវិញទាំងអស់ ដើម្បីកសាងបរិយាកាសសិក្សា និង វប្បធម៌សិទ្ធិមនុស្ស ដែលជាការលុបបំបាត់រាល់ការរើសអើង និង ការកេងប្រវ័ញ្ចលើគ្រប់រូបភាពចំពោះកុមារ ។ កម្មវិធី លើកកម្ពស់សិទ្ធិស្ត្រីនៅជនបទ (RWEP) គឺជាការអភិវឌ្ឍន៍នូវសិទ្ធិស្ត្រីសុខភាពបន្តពូជ ,ភាពយេនឌ័រសម , និង ការពន្យារកំណើត ដែលជាប់ពាក់ព័ន្ធទៅនឹងសិទ្ធិកុមារម្តាយ តាមរយៈការលើកកម្ពស់ការការមិនអាចផ្តាច់ទារកចេញពី , យល់ដឹងអំពីកិច្ចការសង្គម ,នីត្យានុកូលដ្ឋាន ,វប្បធម៌ ,សេដ្ឋកិច្ច ,ការអប់រំ ,ការសម្រេចចិត្តសុ ,ខភាពសិទ្ធិ ,បច្ចេកទេស , ស្មើភាពនិង សេរីភាពក្នុងការបញ្ចេញមតិ ,ការអភិវឌ្ឍ ដោយផ្តោតការយកចិត្តទុកដាក់សំខាន់លើការព្រងឹងសិទ្ធិ និង សម្ថភាពក្នុងការអនុវត្តសកម្មភាពរកប្រាក់ចំណូលរបស់ពួកគេ ដោយមានការជួយគាំទ្រពីបុរស ប្តី/ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច ដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវភាពក្រុមគ្រួសារ និងជាការជម្រុញដល់ការសិក្សារបស់កូនៗឲ្យទទួលបានជោគជ័យនាថ្ងៃអនាគត ។ កម្មវិធីលើកកម្ពស់សិទ្ធជនពិការ និងជនរងគ្រោះដោយសារមីន (PWD/LVSP) សំដៅលើកកម្ពស់ សេដ្ឋកិច្ចវប្បធម៌ និង ,សង្គមកិច្ច , សិទ្ធិជនពិការរួមទាំងជនរងគ្រោះដោយសារមីនផ្តល់ ,ឱកាសដល់កូនៗរបស់ពួកគេមានសិទ្ធិគ្រប់គ្រាន់ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព ។ បច្ចុប្បន្ន អង្គការប្រតិបត្តិការកុមារកម្ពុជា បាន និងកំពុងអនុវត្តផែនការយុទ្ធសាស្ត្រលើកទី២ របស់ខ្លួនពីឆ្នាំ២០១៦-២០២០ ដោយបានកំណត់កម្មវិធីចំនួន ៣ ។

### 2. គោលដៅរួមនៃការត្រួតពិនិត្យការវាយតម្លៃពាក់កណ្តាលអាណត្តិផែនការយុទ្ធសាស្ត្រ:

គោលដៅរួមនៃការត្រួតពិនិត្យវាយតម្លៃផែនការយុទ្ធសាស្ត្រ ២០១-២០២០ នេះ គឺសំដៅធ្វើការផ្ទៀងផ្ទាត់ឡើងវិញ នូវកត្តាជោគជ័យ, ឧបសគ្គទាំងឡាយ, ឬក៏បញ្ហាប្រឈមនានា ដែលបានកើតឡើងក្នុងរយៈពេលពីរឆ្នាំកន្លះនៃការអនុវត្តសកម្មភាពការងាររបស់យើង ។ ចាប់ពីឆ្នាំ ២០១៦ មក កិច្ចការសំខាន់ក្នុងការអនុវត្តកម្មវិធីទាំង ៣, CRDP, PWD/LVSP និង RWEP គឺដើម្បីមើលឲ្យឃើញនូវភាពរីកចម្រើនលើគ្រប់សកម្មភាពទាំងឡាយ ដូចជា៖ ការគ្រប់គ្រងហិរញ្ញវត្ថុ, ការផ្សារភ្ជាប់ការទំនាក់ទំនងពីកម្មវិធីមួយទៅកម្មវិធីមួយ ឬពីគម្រោងមួយទៅគម្រោងមួយទៀត មានជាអាទិ៍ៈ ការចែករំលែកព័ត៌មាន, ការតាមដាន និងការពិគ្រោះយោបល់គ្នា ដើម្បីស្វែងរកឲ្យឃើញនូវចំណុចគួរពង្រឹង ឬបំពេញបន្ថែម សំដៅសម្រេចឲ្យបាននូវគោលដៅយុទ្ធ

សាស្ត្រដែលបានកំណត់ និងគោលបំណងរបស់កម្មវិធី ដែលតម្រូវឲ្យធ្វើការកែសម្រួលឡើងវិញសម្រាប់រយៈពេល ២ឆ្នាំចុងក្រោយ ហួតដល់ដំណាច់ឆ្នាំ ២០២០ ។ គោលដៅរួមនៃការត្រួតពិនិត្យឡើងវិញនេះ គឺដើម្បីធ្វើការសិក្សាប៉ាន់ប្រមាណតាមរយៈការវិភាគស៊ីជម្រៅ, ការសម្រេចបានគោលបំណងរបស់ផែនការយុទ្ធសាស្ត្រ ដើម្បីធ្វើការកែប្រែការប្រើប្រាស់ពេលវេលាដែលនៅ សេសសល់ ផ្សារភ្ជាប់ទៅនឹងការងារគ្រប់គ្រងទិន្នន័យដែលមានស្រាប់, ការគ្រប់គ្រងកម្មវិធី, ការគ្រប់គ្រងគម្រោង និង ការងារទំនាក់ទំនងជាមួយបណ្តាដៃគូ, អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក៏ដូចជាភ្នាក់ងារ/ស្ថាប័នពាក់ព័ន្ធនានា ។

## 3. គោលបំណងនៃការត្រួតពិនិត្យការវាយតម្លៃពាក់កណ្តាលអាណត្តិផែនការយុទ្ធសាស្ត្រ

គោលបំណងនៃការត្រួតពិនិត្យ រួមមាន ៖

១) ធ្វើការប៉ាន់ប្រមាណពីភាពរីកចម្រើននៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ ដោយប្រៀបធៀបទៅនឹងសកម្មភាពគន្លឹះដែលបានកំណត់នៅក្នុងគោលដៅយុទ្ធសាស្ត្រទាំងបី សម្រាប់ឆ្នាំ ២០១៦-២០២០ ។

២) កំណត់បញ្ហាប្រឈមដែលបានជួបប្រទះ, មេរៀនពិសោធន៍ និង ការអនុវត្តន៍ល្អ កម្លុងពេលអនុវត្តផែនការយុទ្ធសាស្ត្រ ព្រមទាំងអន្តរាគមន៍ទាំងឡាយ រយៈពេលពីរឆ្នាំកន្លះនេះ ។

៣) ការរកឲ្យឃើញនូវភាពខ្វះចន្លោះ និង សកម្មភាពទាំងឡាយដែលបានកំណត់ ដើម្បីធ្វើការផ្លាស់ប្តូរ ឬកែលម្អយុទ្ធសាស្ត្រ ក្នុងកិច្ចអន្តរាគមន៍ដែលបានដាក់ចេញ ។

៤) លើកឡើងនូវអនុសាសន៍ ព្រមទាំងធ្វើការកែតម្រូវផែនការយុទ្ធសាស្ត្រ, កែប្រែរបៀបនៃការអនុវត្ត និងការគ្រប់គ្រងគោលការណ៍/គោលនយោបាយនានា ឲ្យសមស្របទៅនឹងតម្រូវការផែនការសម្រាប់ឆ្នាំដែលនៅសល់បន្តបន្ទាប់ទៀត ។

៥) ធ្វើការត្រួតពិនិត្យឡើងវិញនូវគម្រោងដែលមាននៅក្នុងកម្មវិធីនីមួយៗនៃផែនការយុទ្ធសាស្ត្រ ឲ្យសមស្របទៅ នឹងធនធាន ដែលយើងអាចស្នើសុំកិច្ចគាំទ្រអំពីម្ចាស់ជំនួយ ។

## 4. សន្និដានកម្មនៃការត្រួតពិនិត្យការវាយតម្លៃពាក់កណ្តាលអាណត្តិផែនការយុទ្ធសាស្ត្រ

កម្មវិធីចម្បងទាំងបី រួមមាន៖ កម្មវិធី CRDP, PWD/LVSP និង RWEP គឺត្រូវបានរក្សាទុកនៅក្នុងផែនការយុទ្ធ-សាស្ត្រ ២០១៦-២០២០ ដែលបន្តពីផែនការយុទ្ធសាស្ត្រ ២០១១-២០១៥ និង បានផ្តោតការយកចិត្តទុកដាក់ទៅនឹងតម្រូវការចាំបាច់របស់ប្រទេសកម្ពុជាយើង ។ ហេតុនេះការត្រួតពិនិត្យការវាយតម្លៃ គឺជាការកំណត់ទុកជាមុននូវការស្វែងរកឲ្យឃើញចំណុចទាំងឡាយដែលយើងគប្បីត្រូវធ្វើការពង្រឹង ឬបំពេញបន្ថែម ដើម្បីសម្រេចឲ្យបាននូវគោលបំណង និង គោលដៅយុទ្ធសាស្ត្ររបស់កម្មវិធី ដែលទាមទារឲ្យមានការពង្រឹងបន្ថែមលើកិច្ចការទំនាក់ទំនង និង កិច្ចសហប្រតិបត្តិការ ជាមួយប្រភពធនធាន ទាំងខាងក្នុងនិងខាងក្រៅ គួបផ្សំនឹងការប្តេជ្ញាចិត្តក្នុងការចូលរួមអំពីដៃគូពាក់ព័ន្ធនានា ដើម្បីធ្វើឲ្យសម្រេចនូវផែនការ នាដំណាច់ឆ្នាំ ២០២០ ខាងមុខនេះ ។

## 5. ការងារគ្រប់គ្រង និងការសម្របសម្រួលការត្រួតពិនិត្យការវាយតម្លៃពាក់កណ្តាលអាណត្តិផែនការយុទ្ធសាស្ត្រ

គណៈកម្មការគ្រប់គ្រងរបស់ OEC បានចំណាយពេលពេញមួយថ្ងៃ គឺនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៨ ដើម្បីរៀបចំកិច្ចដំណើរការនៃការត្រួតពិនិត្យវាយតម្លៃនេះ ។ បន្ទាប់មក យើងបានធ្វើការសិក្សាលើកម្មវិធីនីមួយៗ ដែលការងារនេះ គឺមានប្រធានកម្មវិធីជាអ្នកដឹកនាំផ្ទាល់ ដោយចំណាយពេល ២ខែ ចាប់ពីខែមិថុនា ដល់ ខែកក្កដា ដើម្បីធ្វើការប្រមូលទិន្នន័យអំពីក្រុមអ្នកដែលត្រូវបានជ្រើសរើសសម្រាប់ការផ្តល់ព័ត៌មាន តាមរយៈការចុះអង្កេត, ការធ្វើសម្ភាសផ្ទាល់, ការប្រជុំពិភាក្សា ដោយប្រើប្រាស់នូវទម្រង់សំណួរ ។ បន្ទាប់មកទើបយើងបញ្ចូលព័ត៌មានដែលប្រមូលបានទៅក្នុងគម្រោងទិន្នន័យ ដោយមានប្រធានកម្មវិធី និង ប្រធានអនុគណៈកម្មការនីមួយៗ ជាអ្នកទទួលខុសត្រូវក្នុងការបញ្ចូលទិន្នន័យទាំងអស់នេះ ។ នៅសប្តាហ៍ទី៤ នៃខែសីហា, អនុគណៈកម្មការប្រមូលទិន្នន័យទាំង៣ ដោយមានការចូលរួមពីសមាជិកគណៈកម្មការគ្រប់គ្រងផងនោះ បានប្រែសម្រួល និង

វិភាគលើកំណត់ត្រា ដែលមាននៅក្នុងទម្រង់ទិន្នន័យ ។ នៅសប្តាហ៍ទី២ ខែកញ្ញា បុគ្គលិករបស់ OEC រួមជាមួយដៃគូពាក់ព័ន្ធសំខាន់ៗ នៅក្នុងតំបន់ប្រតិបត្តិការ រួមមានៈ ថ្នាក់ស្រុក និង ឃុំ ក្នុងខេត្តបាត់ដំបង ធ្វើការវាយតម្លៃរួម និងជាលើកចុងក្រោយលើផែនការយុទ្ធសាស្ត្រឆ្នាំ ២០១៦-២០២០ តាមរយៈការប្រើប្រាស់ឧបករណ៍វិភាគ SWOT ។ កិច្ចការនេះ ស្ថិតក្រោមការសម្របសម្រួលរបស់ប្រធានគណៈកម្មការ ។ ចុងក្រោយបង្អស់ គណៈកម្មការរៀបចំរបាយការណ៍ដែលមានសមាសភាព ៣រូប ជាអ្នកចងក្រងរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃពាក់កណ្តាលអាណត្តិ ដោយគោរពទៅតាមខ្លឹមសារ, កំណត់សម្គាល់ និងអនុសាសន៍ដែលទទួលបានអំពីការវាយតម្លៃរួម ។

## 6. វិន័យរបស់សមាជិកគណៈកម្មការត្រួតពិនិត្យការវាយតម្លៃ

ដើម្បីរក្សានូវតម្លាភាព និងភាពត្រឹមត្រូវច្បាស់លាស់ ការទទួលយកនូវរាល់ការទិទៀនកែលម្អ, មតិយោបល់ និង អនុសាសន៍របស់អ្នកចូលរួម ក៏ដូចជាដៃគូពាក់ព័ន្ធសំខាន់ៗ គឺជាកត្តាដ៏សំខាន់ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង និងសំដៅធ្វើការផ្លាស់ប្តូរជាវិជ្ជមាន ។ ការបង្ហាញនូវទស្សនៈដោយបើកចំហ និងឯករាជ្យភាពរបស់ពួកគេ គឺពុំត្រូវបានជំទាស់ ឬតវ៉ាឡើយ ។ ក្នុងកម្លុងពេលប្រមូលទិន្នន័យ យើងពុំបានកាត់ចោល ឬមួយបំផ្លើសនូវគំនិត ក៏ដូចជាពាក្យពេចន៍របស់អ្នកសម្ភាសន៍ឡើយ ពោលគឺយើងគោរពនូវគោលការណ៍ និងវិធីសាស្ត្រនៃការធ្វើការងារជាក្រុម, សិទ្ធិមូលដ្ឋានសម្រាប់ការអភិវឌ្ឍន៍ ដោយពុំមានការដាក់សម្ពាធ ឬជះឥទ្ធិពលដោយប្រការណាមួយឡើយ ។ ទន្ទឹមនេះ យើងតែងប្រកាន់ខ្ជាប់នូវគោលការណ៍ពិភាក្សាក្នុងការស្វែងរកនូវដំណោះស្រាយផ្សេងៗ ។

# V- យុទ្ធវិធី

## 1. វិធីសាស្ត្រ

1.1. យើងបានចំណាយរយៈពេលពេញមួយថ្ងៃ គឺនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៨ ដើម្បីរៀបចំកិច្ចដំណើរការក្នុងការត្រួតពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិ ដោយបានបង្កើតនូវអនុគណៈកម្មការ និង សមាជិកទាំងឡាយដើម្បីអនុវត្តកិច្ចការនេះ ។ ចាប់ពីថ្ងៃទី២ ខែមិថុនា ដល់ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៨ អនុគណៈកម្មការប្រមូលទិន្នន័យ ដែលមានសមាសភាពចេញមកអំពីបុគ្គលិករបស់គម្រោង និង មានអ្នកគ្រប់គ្រងចំនួន ២រូប បានចាប់ផ្តើមចុះអង្កេត ដោយប្រើប្រាស់នូវទម្រង់សំណួរសម្រាប់ក្រុមអ្នកដែលត្រូវបានជ្រើសរើសសម្រាប់ការផ្តល់ព័ត៌មាន កម្លុងពេលប្រជុំពិភាក្សា, សិក្ខាសាលា, ការប្រជុំពិសេស ឬ ដោយការចុះសម្ភាសផ្ទាល់ជាមួយដៃគូក្នុងតំបន់ ជាពិសេសជាមួយអ្នកផ្តល់សេវាកម្មដែលមានការពាក់ព័ន្ធ ។ បន្ទាប់មក យើងបានស្រង់ព័ត៌មានបញ្ចូលទៅក្នុងទម្រង់ទិន្នន័យ ។ ពីថ្ងៃទី២០ ដល់ ២៤ ខែសីហា ឆ្នាំ២០១៨ អនុគណៈកម្មការប្រមូលទិន្នន័យ បានធ្វើការសិក្សា និងវិភាគទិន្នន័យ ជាមួយនឹងកំណត់ត្រាដែលមាននៅក្នុងទម្រង់ទិន្នន័យស្រាប់ ។

1.2. នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨ អ្នកចូលរួមចំនួន ៥២រូប ពីគ្រប់សមាសភាព រួមមានៈ សមាជិកក្រុមប្រឹក្សានាយក, អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់, បុគ្គលិក OEC, តំណាងស្ថាប័នពាក់ព័ន្ធ, តំណាងអង្គការដៃគូ បានចូលរួមនៅក្នុងអង្គសិក្ខាសាលាមួយ ។ ការរៀបចំវគ្គសិក្ខាសាលានេះ មានគោលបំណងធ្វើការសិក្សា និងវិភាគទៅលើកម្មវិធីទាំង ៣ ដែលបានបង្ហាញនៅក្នុងផែនការយុទ្ធសាស្ត្រ នាពេលព្រឹក ។ ពេលរសៀល យើងបានបែងចែកក្រុមពិភាក្សាជា ៣ក្រុម ដើម្បីធ្វើការឆ្លុះបញ្ចាំងលើចំណុចខ្លាំង, ចំណុចខ្វះខាត, ឱកាស និង ការគម្រាមកំហែង (SWOT analysis) ដោយក្រុមនីមួយៗ គឺពិភាក្សាគ្នាលើកម្មវិធីមួយប៉ុណ្ណោះ ។ បន្ទាប់មក តំណាងក្រុមនីមួយៗឡើងធ្វើបទបង្ហាញពីលទ្ធផលនៃកិច្ចពិភាក្សា និង ជាចុងក្រោយ គឺការបូកសរុបលទ្ធផលដែលទទួលបានពីវគ្គសិក្ខាសាលាទាំងមូល និង បានប្រគល់ជូនទៅគណៈកម្មការរៀបចំរបាយការណ៍ ដែលមានសមាសភាពចំនួន ៣រូប ដើម្បីធ្វើការវិភាគ និង សរសេរពង្រាងរបាយការណ៍ត្រួតពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិដើម្បីដាក់ជូនគណៈកម្មការគ្រប់គ្រងពិនិត្យ និងកែសម្រួលជាលើកចុងក្រោយ ។ ការពិនិត្យលើពង្រាងរបាយការណ៍វាយតម្លៃនេះ ត្រូវចំណាយរយៈពេល ២សប្តាហ៍ ។

 

## 2. ការវិភាគលើបេកាគំហើញ និងការសន្និដ្ឋានៈ

- <u>គោលដៅយុទ្ធសាស្ត្រទី១</u>៖ ជារួម ដើម្បីធ្វើឲ្យសម្រេចជោគជ័យនូវវិធីសាស្ត្រអប់រំសិទ្ធិមនុស្សជាមូលដ្ឋាន ឆ្លើយតបទៅនឹងSDG4 ស្តីអំពីការធានាលើការអប់រំបរិយាប័ន្ន និងគុណភាពនៃការអប់រំប្រកបដោយសមធម៌ ព្រមទាំងការលើកកម្ពស់កាលឱកាសនៃការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ដែលរួមមាន៖ ការធ្វើឲ្យប្រសើរនូវសាលាកុមារមេត្រី, ក្រុមកុមារមេត្រី, សិស្សមជ្ឈមណ្ឌល, បច្ចេកទេសបង្រៀន (Bloom's Taxonomy, Socratic Techniques, Hillarie Bryce Davis, the Four Pillars of Learning by UNESCO) ដែលជាប់ទាក់ទងទៅនឹងមាត្រា២៦ នៃសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស និង មាត្រា២៨ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលបានចែងអំពីសិទ្ធិក្នុងការទទួលបានការអប់រំ, មាត្រា២៩ ស្តីអំពី គោលដៅនៃការអប់រំ ។ ចុងក្រោយបង្អស់ គឺធ្វើការសិក្សាពិចារណាលើការអនុវត្តន៍កម្មវិធីពិភពលោកសម្រាប់ប្រព័ន្ធអប់រំសិទ្ធិមនុស្សនៅកម្រិតបឋម និងមធ្យមសិក្សា ដំណាក់កាលទីមួយ (២០០៥- ២០០៧) ។ ជាចុងក្រោយ គោលដៅយុទ្ធសាស្ត្រទី១ របស់យើង បានជ្រើសយកយុទ្ធវិធីចំនួន៤ មកប្រើប្រាស់ គឺ៖
  - ក) ដើម្បីលើកកម្ពស់ការទទួលបានសមភាពក្នុងការអប់រំប្រកបដោយគុណភាពល្អ តាមរយៈការឧបត្ថម្ភដល់កុមាររស់នៅក្នុងតំបន់ជួបការលំបាក ដើម្បីឲ្យពួកគេបានចូលរៀននៅតាមសាលាដែលយើងបានផ្តួចផ្តើមរៀបចំឡើង,
  - ខ) ដើម្បីលើកកម្ពស់ឱកាសសិក្សា តាមរយៈការជួយគាំទ្រដល់កុមារដែលបានបោះបង់ការសិក្សា មានលទ្ធភាពបន្តការសិក្សាប្រកបដោយផាសុខភាព,
  - គ) ដើម្បីអនុវត្តតាមសេចក្តីថ្លែងការណ៍ នៅ អ៊ីនឈន ក្រោមការផ្តួចផ្តើម និងរៀបចំដោយ UNESCO ដើម្បីអនុវត្ត SDG4,
  - ឃ) ដើម្បីអនុវត្តកម្មវិធីពិភពលោកសម្រាប់ការអប់រំសិទ្ធិមនុស្សនៅកម្រិតបឋម និងមធ្យមសិក្សា (ដំណាក់កាល ២០០៥-២០០៧) ដែលនៅពុំទាន់សម្រេចគោលដៅនៅឡើយ ។

<u>សេចក្តីសន្និដ្ឋាន និងអនុសាសន៍:</u>

ដើម្បីរក្សាទុកឲ្យនៅដដែល កម្មវិធី លើកកម្ពស់ការអភិវឌ្ឍន៍សិទ្ធិកុមារ នៅក្នុងផែនការយុទ្ធសាស្ត្ររបស់យើង ឆ្នាំ ២០១៦-២០២០ អង្គការប្រតិបត្តិការកុមារកម្ពុជាគួរខិតខំប្រឹងប្រែងក្នុងការស្វែងរកកិច្ចគាំទ្រអំពីម្ចាស់ជំនួយដែលសមស្រប ដើម្បីគាំទ្រដល់ កម្មវិធីអប់រំសិទ្ធិមនុស្សនៅក្នុងប្រព័ន្ធអប់រំកម្រិតបឋម និង មធ្យមសិក្សា សំដៅជម្រុញនូវវិធីសាស្ត្ររៀន និងបង្រៀន ក៏ដូចជាពង្រឹង វិធីសាស្ត្រអប់រំមូលដ្ឋានសិទ្ធិមនុស្សផងដែរ ។

- **គោលដៅយុទ្ធសាស្ត្រទី២**៖ ដើម្បីលើកកម្ពស់សិទ្ធិជនពិការ និងជនរងគ្រោះដោយសារមីន ដោយផ្អែកតាមអនុសញ្ញាស្តីពីសិទ្ធិជនពិការ និង គោលការណ៍ចម្បងៗទាំង ៨ នៃអនុសញ្ញា (ការគោរពសេចក្តីថ្លៃថ្នូរដែលមានស្រាប់, ស្វ័យភាពបុគ្គលរួមទាំងសេរីភាពក្នុងជម្រើសផ្ទាល់ខ្លួន, ឯករាជ្យភាពបុគ្គល; គ្មានភាពរើសអើង; ការចូលរួមប្រកបដោយប្រសិទ្ធិភាពពេញលេញនៅក្នុងសង្គមជាតិ; សេចក្តីគោរពចំពោះភាពខុសគ្នា និងការទទួលស្គាល់ជនពិការ គឺជាចំណែក

មួយនៃភាពសម្បូណ៌បែបរបស់មនុស្សជាតិ; សមភាពនៃកាលឳកាស; ការសម្របសម្រួល; សមភាពរវាងបុរសនិងស្ត្រី; ការគោរពចំពោះសមត្ថភាពអភិវឌ្ឍន៍ផ្ទាល់របស់កុមារពិការ និងការគោរពសិទ្ធិរបស់កុមារពិការ ដើម្បីរក្សាការពារអត្តសញ្ញាណកម្មរបស់ពួកគេ), ច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ជាពិសេសគឺមាត្រា៣៩ ច្បាប់ស្តីពីការអប់រំនៅប្រទេសកម្ពុជា បានចែងថា៖ សិស្សពិការមានសិទ្ធិ និងទទួលបានការអប់រំដូចសិស្សទូទៅដទៃទៀតដែរ ។ ជនពិការរស់នៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប ភាគច្រើនពួកគេត្រូវបានការពារដោយ៖

- SDG1 : គ្មានភាពក្រីក្រៈ បញ្ចប់ភាពក្រីក្រលើគ្រប់ទម្រង់ និងគ្រប់ទីកន្លែងទាំងអស់,
- SDG2: គ្មានការអត់ឃ្លានៈ បញ្ចប់ភាពអត់ឃ្លាន, ការទទួលបានសន្តិសុខស្បៀង និង ការធ្វើឲ្យភាពប្រសើរឡើងនូវអាហារូបត្ថម្ភ រួមទាំងការលើកកម្ពស់និរន្តរភាពកសិកម្ម,
- SDG3: សុខភាពល្អៈ ធានាបាននូវសុខភាពល្អ និងសុខុមាលភាពសម្រាប់មនុស្សគ្រប់រូប និងគ្រប់វ័យ,
- SDG4: គុណភាពអប់រំៈ ធានាលើការអប់រំបរិយាប័ន្ន និងគុណភាពអប់រំប្រកបដោយសមធម៌ ព្រមទាំងការលើកកម្ពស់កាលឱកាសនៃការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ។ ជាការពិត គ្រប់គោលដៅអភិវឌ្ឍ ប្រកបដោយចីរភាព (SDG) ទាំង១៧ គឺមានការរួមបញ្ចូលការលើកកម្ពស់គុណភាពជនពិការ ព្រោះថាពួកគាត់ក៏ជាមនុស្សជាតិដែរ ហើយ SDG គឺមានគោលការណ៍ជាសកល និងមូលដ្ឋានគ្រឹះសិទ្ធិមនុស្សដ៏រឹងមាំ ។

គោលដៅយុទ្ធសាស្ត្រទី២ របស់យើង បានជ្រើសយកយុទ្ធវិធីចំនួន៤ មកប្រើប្រាស់ គឺ៖

ក) អំពាវនាវរកម្ចាស់មូលនីធិ ដើម្បីគាំទ្រលើ គម្រោង៖ ការលើកកម្ពស់ជីវភាព និង សុខុមាលភាពគ្រួសារជនពិការក្រោមហេតុផល (គោរពតាមស្មារតីនៃ SDG1) មានចំនួន 20%, ជនពិការគ្រប់ប្រភេទ 50%, ជនរងគ្រោះដោយសារមីន 30% ដែលបានកំណត់ក្នុងមួយឆ្នាំ គឺត្រូវជ្រើសរើស (តាមការជ្រើសឆ្លាស់គ្នា) ចំនួន ៣០០គ្រួសារ តាមបណ្តាខេត្តចំនួន ៥ ដែលមានព្រំប្រទល់ជាប់នឹងប្រទេសថៃឡង់ដ៍ និង ជាតំបន់ដែលស្ថិតក្រោមឥទ្ធិពលនៃ ជម្លោះប្រដាប់អាវុធដ៏រ៉ាំរ៉ៃ ហើយដែលមានតម្រូវការនូវកិច្ចគាំទ្រជាចាំបាច់ (ខេត្តបាត់ដំបង, ប៉ៃលិន, បន្ទាយមាន ជ័យ, ឧត្តរមានជ័យ និង ព្រះវិហារ) ។ ចំពោះយុទ្ធសាស្ត្រខាងលើនេះ គឺយើងនៅពុំទាន់បានសម្រេចតាមផែនការ នៅឡើយទេ ។

ខ) ធ្វើការពង្រឹងនូវជំនឿទុកចិត្តលើខ្លួនឯង និង ភាពថ្លៃថ្នូរផ្ទាល់ខ្លួនរបស់ជនពិការ តាមរយៈការអប់រំសិទ្ធិ (UDHR, CRC, CEDAW, ICRPWD, ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ស្តីពី កិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ, ច្បាប់ស្តីពី ការទប់ស្កាត់ការប្រើអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការការពារជនរងគ្រោះ, ច្បាប់ស្តីពីការរៀបអាពាហ៍ ពិពាហ៍និងគ្រួសារ, ច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រាសំខាន់ៗមួយចំនួនទៀតនៃក្រមព្រហ្មទណ្ឌកម្ពុជា)។ យុទ្ធសាស្ត្រនេះ ក៏យើងពុំទាន់សម្រេចបានតាមផែនការនៅឡើយដែរ ។

គ) ការកែលម្អជីវភាពរស់នៅរបស់ជនពិការ តាមរយៈការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ អាស្រ័យលើការសម្រេចចិត្តផ្ទាល់របស់អ្នកចូលរួម ដូចជាៈ ការដាំដំណាំ, ចិញ្ចឹមសត្វ, ដំណាំតាមរដូវកាល, ការបណ្តុះបណ្តាលការងារគ្រប់គ្រងមុខរបរខ្នាតតូច និង ការសិក្សាលើតម្រូវការទីផ្សារ ។ ជាចុងក្រោយ គឺយើងមានផ្តល់ជាធនធានសម្ភារសម្រាប់ដំណើរការសកម្មភាពមុខរបរ ចំពោះគ្រួសារណាដែលគាត់មានឆន្ទៈ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការចាប់ផ្តើមអនុវត្តមុខរបរផ្ទាល់ខ្លួនរបស់ពួកគាត់បាន ។ យុទ្ធសាស្ត្រនេះ ក៏យើងពុំទាន់សម្រេចបានតាមផែនការនៅឡើយដែរ ។

ឃ) ផ្តល់ការឧបត្ថម្ភជាសម្ភារសិក្សា, ឯកសណ្ឋានសិស្ស ដល់កូនៗរបស់ជនពិការ ព្រមទាំងមធ្យោបាយធ្វើដំណើរសម្រាប់សិស្សានុសិស្សដែលមានលំនៅដ្ឋានឆ្ងាយពីសាលា ដើម្បីឲ្យពួកគេចូលរៀនបានទៀងទាត់ ឆ្លើយតបទៅនឹង SDG4, លុបបំបាត់រាល់ការរើសអើងក្នុងវិស័យអប់រំ ព្រមទាំងរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ។ យុទ្ធសាស្ត្រនេះ ក៏នៅពុំទាន់សម្រេចបានតាមផែនការនៅឡើយដែរ ។

<u>កំណត់សម្គាល់៖</u>

ក្នុងកម្លុងពេលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិនេះ អង្គការប្រតិបត្តិការកុមារកម្ពុជាពុំទាន់មានលទ្ធភាពក្នុងការស្វែងរកម្ចាស់មូលនិធិជាក់លាក់ណាមួយដើម្បីគាំទ្រនូវកម្មវិធីនេះនៅឡើយទេ ។ សិទ្ធិរបស់កុមារពិការ គឺត្រូវបានដាក់បញ្ចូលនៅក្នុងការអប់រំបរិយាប័ន្ន, គម្រោងកិច្ចការពារប្រឆាំងនឹងការរំលោភបំពានគ្រប់រូបភាពលើកុមារ តាមរយៈការបង្កើតជាសមាគមមាតាបិតា, សកម្មភាពក្លឹបកុមារ ដែលបានឧបត្ថម្ភដោយ BICE/Oak Foundation, MISEREOR and KINDERMISSIONS-WERK, និង កម្មវិធីអប់រំបរិយាប័ន្ន ដែលទទួលបានការគាំទ្រថវិកាអំពី Save the Children/Aide et Action និង IKEA ។ អង្គការប្រតិបត្តិការកុមារកម្ពុជា ធ្លាប់បានដំណើរការយ៉ាងសកម្មនូវគម្រោង លើកកម្ពស់សិទ្ធិជនពិការដោយសារមីន ដែលបានឧបត្ថម្ភដោយ Adopt-A-Minefield ចាប់តាំងពីឆ្នាំ ២០០៣ ដល់ ២០១៥ ។

<u>សេចក្តីសន្និដ្ឋាន និងអនុសាសន៍:</u>

យើងបានរក្សាជានិច្ចនូវ កម្មវិធី លើកកម្ពស់សិទ្ធិជនពិការនិងជនរងគ្រោះដោយសារមីន នៅក្នុងផែនការយុទ្ធសាស្ត្រឆ្នាំ ២០១៦-២០២០ របស់យើងឲ្យនៅងដែល ។ តាមរយៈលទ្ធផលជំរឿនឆ្នាំ ២០០៨ បានបង្ហាញថា ក្នុងចំណោមប្រជាពលរដ្ឋចំនួន ១៣.៨៩៥.៦៨២នាក់ មានជនពិការចំនួន ២៨.៤៣៤នាក់ រស់នៅតាមតំបន់ជាយក្រុង/ទីប្រជុំជន និងមាន ១៦៤,១០៤នាក់ រស់នៅតាមតំបន់ជនបទ ។ ដោយឡែក នៅក្នុងខេត្តបាត់ដំបង គឺមានចំនួន ១០,២៦% ដែលក្នុងនោះមានជនពិការចំនួន ០,៧០% រស់នៅតាមតំបន់ជាយក្រុង/ទីប្រជុំជន និង ៩,៧៦% រស់នៅតាមតំបន់ជនបទ ។ ហេតុនេះ អង្គការប្រតិបត្តិការកុមារកម្ពុជា គប្បីព្យាយាមស្វះស្វែងរកអង្គការនានា ដើម្បីជួយគាំទ្រដល់ជនពិការក្រីក្រទាំងអស់នោះ ។

- **គោលដៅយុទ្ធសាស្ត្រទី៣ ៖** ដើម្បីធ្វើឲ្យសម្រេចនូវមាត្រា ១៤ នៃ CEDAW ដែលផ្តោតសំខាន់លើបញ្ហាប្រឈមជាក់លាក់របស់ស្ត្រីនៅជនបទបានជួបប្រទះ រួមទាំងការចូលរួមក្នុងការកសាងផែនការអភិវឌ្ឍន៍, លទ្ធភាពក្នុងការទទួលបានការថែទាំសុខភាពសមស្រប, កិត្តិយស, ការអប់រំ, ជីវភាពសមរម្យ និង គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៥ គឺធ្វើឲ្យសម្រេចបានសមភាពយេនឌ័រ និងលើកកម្ពស់អំណាចស្ត្រី រួមទាំងកុមារីគ្រប់ៗគ្នា ដោយគោរពទៅតាមសេចក្តីថ្លែងការណ៍នៃសន្និសីទពិភពលោក ដែលរៀបចំឡើងនៅទីក្រុងប៉េកាំងនាឆ្នាំ១៩៩៥ បានថ្លែងថា៖ សិទ្ធិនារី គឺជាសិទ្ធិរបស់មនុស្សលោកគ្រប់រូប ។ ការលុបបំបាត់ភាពក្រីក្រ តម្រូវឲ្យមានការចូលរួមពីស្ត្រី ក្នុងការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច, សង្គម និង សមភាពនៃកាលឱកាសរវាងស្ត្រីនិងបុរស ដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព, ការចូលរួមអនុវត្តយ៉ាងពេញលេញនូវសិទ្ធិមនុស្ស អាស្រ័យដោយមានការចូលរួមអំពីស្ត្រី និងកុមារីគ្រប់ៗរូប ក៏ដូចជាលុបបំបាត់រាល់ការរើសអើង និងប្រើអំពើហិង្សាលើពួកគេផងដែរ ។ តាមរយៈសារនេះ នាឱកាសខួបទិវានារីអន្តរជាតិ លោក បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ បានគូសបញ្ជាក់ដូចខាងក្រោមថា៖ « ក្នុងខណៈដែលយើងឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ទី២ តាមការកំណត់បាន គឺជាពេលវេលាដែលត្រូវធ្វើការវិនិយោគបន្ថែមទៅលើស្ត្រីនៅជនបទ, ការការពារសិទ្ធិ ព្រមទាំងការកែលម្អស្ថានភាពរបស់ពួកគេ» ។ យុទ្ធសាស្ត្រទី៣ គឺយើងប្រើប្រាស់វិធីសាស្ត្រចំនួន ៤ ៖

  ក) ការអប់រំសិទ្ធិមនុស្ស៖ បើកវគ្គសិក្ខាសាលាបណ្តុះបណ្តាលដល់ស្ត្រីនៅជនបទ ដោយប្រើវិធីរៀនសូត្ររបស់មនុស្សពេញវ័យ និង ការរៀនសូត្រអន្តរសហការ តាមបច្ចេកទេសសូក្រាត ដែលនាំឲ្យមានការពិភាក្សាគ្នា និងការវិភាគរបស់ UDHR, CRC, CEDAW, ICRPWD, ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ, ច្បាប់ស្តីពីការទប់ស្កាត់ការប្រើអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការការពារជនរងគ្រោះ, ច្បាប់ស្តីពីការរៀបអាពាហ៍ពិពាហ៍និងគ្រួសារ, ច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ និង មានមាត្រាសំខាន់ៗមួយចំនួនទៀត នៃក្រមព្រហ្មទណ្ឌកម្ពុជា ។ ច្បាប់ទាំងនេះ គឺសំដៅធ្វើការពង្រឹងនូវភាពថ្លៃថ្នូរ, ជម្រុញការជឿទុកចិត្តលើខ្លួនឯង និងការចូលរួមយ៉ាងសកម្មដោយស្មើភាពគ្នាលើវិស័យសេដ្ឋកិច្ច, សង្គម, វប្បធម៌ និង នយោបាយ ដើម្បីធ្វើការអភិវឌ្ឍសហគមន៍ជនបទឲ្យមាននិរន្តភាព ។ ការអប់រំអំពីសិទ្ធិមនុស្ស គឺសំដៅធ្វើឲ្យស្ត្រីនៅតាមជនបទ មានការយល់ដឹងអំពីសមត្ថភាពផ្ទាល់ ព្រមទាំងធ្វើការផ្លាស់ប្តូរខ្លួនឯង ក្រុមគ្រួសារ និង សហគមន៍របស់ពួកគេ ។ យុទ្ធសាស្ត្រនេះ យើងពុំទាន់សម្រេចបានតាមផែនការនៅឡើយ ។

ខ) សមភាពយេនឌ័រ៖ រៀបចំវគ្គសិក្ខាសាលាបណ្តុះបណ្តាល ដោយមានការចូលរួមទាំងបុរសនិងស្ត្រី ដើម្បីជាការលើកកម្ពស់ដល់ការអនុវត្តន៍សមភាពយេនឌ័រ ពីព្រោះបើគ្មានការចូលរួមយ៉ាងទូលំទូលាយអំពីបុរស និងកុមារាទេនោះ សមភាព ក៏ពុំអាចកើតមានឡើងបានដែរ ។ ជាដំបូង ត្រូវដឹកនាំកិច្ចពិភាក្សា និងវិភាគស៊ីជម្រៅទៅលើ មាត្រា 1, 2, 3, 4, 5, 6, 7, 27 និង 30 នៃ UDHR បន្ទាប់មកធ្វើការវិភាគលើ មាត្រា 1, 2, 3, 4, 5 នៃ CEDAW, និងអនុសាសន៍ទូទៅ នៅក្នុងមាត្រា 2, 5, 11, 12, 16 ដោយប្រៀបធៀបទៅនឹងគុណតម្លៃរបស់គោលដៅអភិវឌ្ឍន៍ប្រកដដោយចីរភាពទី៥ និង ធ្វើសំយោគបញ្ចប់វគ្គ ដោយបញ្ជាក់ពីខ្លឹមសារនៃសមភាពយេនឌ័រ គឺជាប្រភពធនធានដ៏សំខាន់ក្នុងការកសាងសុភមង្គល និងសេចក្តីថ្កុំថ្កើងរុងរឿងក្នុងក្រុមគ្រួសារ ។ បន្ទាប់មកទៀត ត្រូវដឹកនាំកិច្ចពិភាក្សាបន្តដោយធ្វើការប្រៀបធៀបសមភាពយេនឌ័រ ទៅនឹងសិទ្ធិមនុស្ស ដែលនាំឲ្យអ្នកចូលរួមយល់ជ្រួតជ្រាបអំពីគោលការណ៍នៃការគោរពគ្នាទៅវិញទៅមក, សុខភាពបន្តពូជ និងសុវត្ថិភាពផ្លូវភេទ, លទ្ធផលនៃការអនុវត្តន៍ចុងក្រោយ គឺការពន្យារកំណើត ដែលជាផ្នែកមួយក្នុងការកាត់បន្ថយភាពក្រីក្រ និង ដើម្បីផាសុខភាពក្នុងក្រុមគ្រួសារ ។ យុទ្ធសាស្ត្រនេះ យើងពុំទាន់សម្រេចបានតាមផែនការនៅឡើយទេ ។

គ) សុខភាពស្ត្រីនៅជនបទ៖ តាមរយៈវគ្គសិក្ខាសាលាបណ្តុះបណ្តាល និង កិច្ចសន្ទនាគ្នានេះ ស្ត្រីជនបទនៅទទួលបានការបណ្តុះបណ្តាលលើ ការអនុវត្តន៍ការធ្វើអនាម័យ និងសុខភាព, ការថែរក្សាគភ៌, អាហារូបត្ថម្ភ (អាហារ ៣ក្រុម, អាហារូបត្ថម្ភក្នុងកម្លុងពេលមានផ្ទៃពោះ និងពេលបំបៅដោះកូន, អាហារបំប៉នសម្រាប់ទារកដែលមានអាយុពី ៦ ដល់ ៨ខែ, ពី ៩ ដល់ ១២ខែ, ពី ១ឆ្នាំដល់ ៣ឆ្នាំ, ពី ៤ ទៅ ៨ឆ្នាំ, ពី ៩ ទៅ ១២ឆ្នាំ, ពី ១៣ ទៅ ១៨ឆ្នាំ និង ពី ១៩ ទៅ ២១ឆ្នាំ) ។ ការយល់ដឹងអំពីការបង្ការនិងការពារជម្ងឺរបេង, រាករូស និងជម្ងឺគ្រុនចាញ់, លក្ខណៈខុសគ្នារវាងមូសដែកគោលនិងមូសដទៃ ។ យុទ្ធសាស្ត្រនេះ គឺបានអនុវត្តដោយគម្រោងនូវីស ដែលកំពុងប្រតិបត្តិការនៅក្នុងស្រុកចំនួន ៩ របស់ខេត្តបាត់ដំបង ។

ឃ) សកម្មភាពបង្កើនប្រាក់ចំណូល ៖ រៀបចំជាវគ្គបណ្តុះបណ្តាលមុខជំនាញបច្ចេកទេស សម្រាប់ស្ត្រីនៅជនបទ ដោយផ្អែកលើការសម្រេចចិត្តរបស់អ្នកចូលរួម ដូចជា៖ ការដាំដំណាំ, ចិញ្ចឹមសត្វ, ការដាំបន្លែ និងដំណាំតាមរដូវកាល ។ ក្រៅពីវិស័យកសិកម្ម ស្ត្រីនៅជនបទអាចរៀនមុខជំនាញផ្សេងៗទៀតផងដែរ ដូចជា៖ កាត់ដេរ, ធ្វើនំ ឬ ចំណីអាហារជាដើម ។ បន្ទាប់មក យើងនឹងមានការរៀបចំវគ្គបណ្តុះបណ្តាលទូទៅមួយសម្រាប់ពួកគេ ពាក់ព័ន្ធទៅនឹងការសិក្សាអំពីស្ថានភាពភូមិសាស្ត្រ, កត្តាសេដ្ឋកិច្ចដែលអាចជះឥទ្ធិពលលើទីផ្សារ, ការប៉ាន់ប្រមាណទីផ្សារ រួមជាមួយតម្រូវការ និងកត្តាអ្នកផ្គត់ផ្គង់, វិធីសាស្ត្រទាក់ទាញទឹកចិត្តអតិថិជន, ការកំណត់ហានីភ័យ, ការយល់ដឹងអំពីការគ្រប់គ្រងចំណូល/ចំណាយ ។ ជាចុងក្រោយ គឺការសម្រេចចិត្តក្នុងការជ្រើសរើសមុខរបរដែលសមស្របទៅនឹងលទ្ធភាព និង សមត្ថភាពរបស់ពួកគាត់ ។ យុទ្ធសាស្ត្រនេះ យើងពុំទាន់សម្រេចបានតាមផែនការនៅឡើយទេ ។

<u>**សេចក្តីសន្និដ្ឋាន និងអនុសាសន៍:**</u>

យើងនឹងរក្សាទុកជានិច្ចនូវ កម្មវិធី លើកកម្ពស់សិទ្ធិស្ត្រីនៅជនបទ ក្នុងផែនការយុទ្ធសាស្ត្រ ២០១៦-២០២០ ឲ្យនៅដដែល សំដៅបំពេញនូវមាត្រា១៤ នៃ CEDAW and SDG5 ដែលជាការឆ្លើយតបជាក់ស្តែងទៅនឹងស្ថានភាពបច្ចុប្បន្នរបស់ប្រទេសកម្ពុជាយើង ។ អង្គការប្រតិបត្តិការកុមារកម្ពុជា គប្បីព្យាយាមស្វះស្វែងរកម្ចាស់ជំនួយ ក្នុងការបម្រើឲ្យយុទ្ធសាស្ត្រដែលបានលើកឡើងនៅក្នុងគម្រោងផែនការ (ការអប់រំសិទ្ធិមនុស្ស, សមភាពយេនឌ័រ, សុខភាពស្ត្រីនៅជនបទ និង សកម្មភាពបង្កើនប្រាក់ចំណូល) ។

**២.១. <u>ការចូលរួមរបស់អាជ្ញាធរដែនដី និងសមាជិកសហគមន៍:</u>**

គម្រោងចំនួន៨ របស់ កម្មវិធីអភិវឌ្ឍសិទ្ធិកុមារ (CRDP) និង គម្រោង នូវីស នៃកម្មវិធីលើកកម្ពស់សិទ្ធិស្ត្រីនៅតាមជនបទ(RWEP) ដែលបាននិងកំពុងអនុវត្តនៅតាមបណ្តាស្រុកគោលដៅ គឺទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅ ពីសំណាក់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់, គណៈកម្មការឃុំទទួលបន្ទុកកិច្ចការនារីនិងកុមារ, ថ្នាក់ដឹកនាំមន្ទីរ/ការិយាល័យអប់រំយុវជននិងកីឡា ព្រមទាំងស្ថាប័នពាក់ព័ន្ធសំខាន់ៗ បានផ្តល់ឱកាសដ៏ទូលំទូលាយដល់ក្រុមការងាររបស់គម្រោងរបស់យើងទាំងអស់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការធ្វើឲ្យសម្រេចបាននូវគោលដៅរបស់គម្រោងទាំងមូល ។

២.២. ការងារគ្រប់គ្រងហិរញ្ញវត្ថុ:

ចាប់តាំងពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៨ របាយការណ៍ហិរញ្ញវត្ថុរួមប្រចាំឆ្នាំរបស់យើង ត្រូវបានរៀបចំឡើង និងផ្សព្វផ្សាយយ៉ាងទៀងទាត់ តាមរយៈ Web site www.oecbtb.org ។ របាយការណ៍របស់យើង ជានិច្ចជាកាលគឺមានតម្លាភាពត្រឹមត្រូវ និង ពុំមានបញ្ហាអ្វីគួរឲ្យកត់សម្គាល់ លើការប្រើប្រាស់ថវិកាហួសពីដែនកំណត់ ឬក៏ប្រាសចាកពីគោលនយោបាយរបស់អង្គភាព ដែលបានចែងនោះឡើយ ។ សវនកម្មរួមរបស់អង្គការ ត្រូវបានអនុវត្តដោយស្ថាប័នឯករាជ្យមួយគឺ KPMG និងមានការព្រមព្រៀងពីម្ចាស់ជំនួយផ្ទាល់ ហើយដែលមកទល់នឹងពេលបច្ចុប្បន្ននេះ អង្គការយើងពុំទាន់មានលេចចេញនូវបាតុភាពដែលមិនប្រក្រតីណាមួយ នៅក្នុងការប្រើប្រាស់ថវិកាជំនួយនោះឡើយ ។

# VI- សេចក្តីសន្និដ្ឋាន

ក) សមិទ្ធិផល:

ជាដំបូង អង្គការប្រតិបត្តិការកុមារកម្ពុជាបានបង្កើតដោយជោគជ័យនូវកម្មវិធីចំនួន ៣ គឺៈ កម្មវិធី លើកកម្ពស់ការអភិវឌ្ឍសិទ្ធិកុមារ (CRDP), កម្មវិធី លើកកម្ពស់សិទ្ធិជនពិការនិងជនរងគ្រោះដោយសារមីន (PWD/LVSP) និង កម្មវិធីលើកកម្ពស់សិទ្ធិស្ត្រីនៅតាមជនបទ (RWEP) ក្នុងនោះមានពហុគម្រោងបានរួមបញ្ចូលគ្នា ដែលមានការគ្រប់គ្រង និងសម្របសម្រួលជាផ្នែកៗ ដើម្បីសម្រេចនូវគោលដៅ, លទ្ធផល និង ផ្តល់អត្ថប្រយោជន៍ដល់ក្រុមគោលដៅនៅតាមសហគមន៍ ។ កម្មវិធីលើកកម្ពស់ការអភិវឌ្ឍសិទ្ធិកុមារ (CRDP) គ្របដណ្តប់ដោយគម្រោងចំនួន ៨, កម្មវិធី លើកកម្ពស់សិទ្ធិស្ត្រីនៅជនបទ (RWEP) មាន ១គម្រោង ដែលអនុវត្តនូវ MDG5 ដើម្បីលើកកម្ពស់សុខភាពមាតា ។ គ្រប់កម្មវិធីទាំង ៣ នៅក្នុងផែនការយុទ្ធសាស្ត្ររបស់យើង សុទ្ធតែត្រូវបានបំពេញនូវផ្នែកសំខាន់ៗប្រកបដោយជោគជ័យ លើកលែងតែកម្មវិធី លើកកម្ពស់សិទ្ធិជនពិការ និងជនរងគ្រោះដោយសារមីន (PWD/LVSP) ដែលពុំទាន់ត្រូវបានម្ចាស់ជំនួយគាំទ្រនៅឡើយ ក៏ប៉ុន្តែសិទ្ធិជនពិការ ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីអប់រំរបស់គម្រោងទាំង ៨ ។ ការអប់រំសិទ្ធិមនុស្ស គឺយើងជ្រើសរើសនៅក្នុងកម្រងសាលាបឋមសិក្សា រីឯសកម្មភាពពេញលេញនៃកម្មវិធីលើកកម្ពស់សិទ្ធិស្ត្រីនៅជនបទ នឹងក្លាយជាប្រធានបទសម្រាប់ការស្វែងរកថវិកានាពេលអនាគត ។ បន្ថែមពីនោះ អង្គការប្រតិបត្តិការកុមារកម្ពុជា បាននិងកំពុងសហការយ៉ាងជិតស្និទ្ធជាមួយអង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជា (Habitat for Humanity) ដើម្បីផ្តល់ការគាំទ្រលើការសាងសង់ ក៏ដូចជាកែលម្អលំនៅដ្ឋានរបស់ប្រជាពលរដ្ឋក្រីក្រ នៅក្នុងស្រុកគោលដៅចំនួន ៣ ។

ខ) កត្តាសម្របសម្រួល:

គម្រោងភាគច្រើនដែលមាននៅក្នុងកម្មវិធី CRDP និង កម្មវិធី RWEP គឺស្របគ្នាទៅនឹងនិន្នាការរបស់ម្ចាស់ជំនួយ និង ជាការឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សហគមន៍ ។ បុគ្គលិកយើងទាំងអស់ គឺមានការអប់រំល្អ មានការប្តេជ្ញាចិត្តខ្ពស់ក្នុង ការបំពេញបេសកកម្មលើគ្រប់ស្ថានភាពទាំងអស់ដែលកើតមានឡើងនៅតាមតំបន់គោលដៅ ។ គ្រប់គម្រោងទាំងអស់ តែងទទួល បាននូវកិច្ចស្វាគមន៍ និង មានការចូលរួមសហប្រតិបត្តិការ ពីសហគមន៍ ក៏ដូចជាអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ។

គ) ឧបសគ្គ:

ការព្យាយាមក្នុងការស្វែងរកថវិកា សម្រាប់អនុវត្តសកម្មភាពអប់រំសិទ្ធិមនុស្សនៅក្នុងកម្រងសាលាបឋមសិក្សា ដែលជាការរួមចំណែកក្នុងការពង្រឹងលើការគោរពសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន រួមជាមួយនឹងការលើកកម្ពស់ការរៀន និងបច្ចេកទេសបង្រៀន, ការបណ្តុះបុគ្គលិកលក្ខណៈរបស់កុមារ និង សកម្មភាពផ្សេងៗ ដើម្បីជាការបំពេញឲ្យការលើកកម្ពស់សិទ្ធិស្ត្រីនៅជនបទ ឆ្លើយតបទៅនឹងមាត្រា១៤ នៃ CEDAW និង SDG5 និង ដើម្បីធ្វើឲ្យសម្រេចបានផែនការយុទ្ធសាស្ត្រឆ្នាំ 2016-2020, មកទល់បច្ចុប្បន្ននេះ គឺអង្គការប្រតិបត្តិការកុមារកម្ពុជាយើងពុំទាន់សម្រេចបាននៅឡើយ ។

ឃ) អនុសាសន៍:

អង្គការប្រតិបត្តិការកុមារកម្ពុជា គួរសិក្សាលើពេលវេលាផែនការយុទ្ធសាស្ត្រដែលនៅសេសសល់ ដើម្បីខិតខំស្វះស្វែងក្នុងការរៀអង្គាសថវិកា ដើម្បីអនុវត្តកម្មវិធីអប់រំសិទ្ធិមនុស្សនៅកម្រិតបឋម និងមធ្យមសិក្សា គោរពតាមកម្មវិធីពិភពលោកសម្រាប់ការអប់រំសិទ្ធិមនុស្ស ជាពិសេសគឺមាត្រា២៦ នៃ UDHR និង ដើម្បីពង្រឹងដល់ថ្នាក់រៀន ព្រមទាំងក្រុមប្រឹក្សាកុមារដែលមានស្រាប់ សំដៅកសាងការទំនាក់ទំនងជាវិជ្ជមានរវាងគ្រូបង្រៀន និងសិស្សានុសិស្ស ។ ក្រៅពីនោះ អង្គការប្រតិបត្តិការកុមារកម្ពុជាគួរព្យាយាមឲ្យអស់ពីសមត្ថភាពរបស់ខ្លួនផងដែរ ក្នុងការធ្វើឲ្យសម្រេចនូវការលើកកម្ពស់សិទ្ធិស្ត្រីនៅជនបទ ជាការឆ្លើយតបទៅនឹងមាត្រា១៤ នៃ CEDAW និង SDG5 ព្រមទាំងឈានទៅសម្រេចនូវសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងកុមារីគ្រប់ៗរូប ទាក់ទងទៅនឹង សន្និសីទពិភពលោកលើកទី៤ ស្តីអំពីស្ត្រី ដែលបានរៀបចំឡើងនាទីក្រុងប៉េកាំង ។ ទន្ទឹមនេះ ក៏ត្រូវខិតខំអំពាវនាវរកម្ចាស់មូលនិធិ សម្រាប់កម្មវិធីលើកកម្ពស់សិទ្ធិជនពិការ និងជនរងគ្រោះដោយសារមីនផងដែរ ដោយធ្វើការសិក្សាពិចារណាលើលទ្ធផលជំរឿនស្ថិតិជនពិការ ក្នុងឆ្នាំ២០០៨ ដែលបង្ហាញថា៖ នៅក្នុងខេត្តបាត់ដំបង មានជនពិការសរុបចំនួន 10.26% ក្នុងនោះមានជនពិការចំនួន 9.70% រស់នៅតាមតំបន់ជាយក្រុង/ទីប្រជុំជន និង10.47% រស់នៅតាមជនបទ ។

## VII- ជំហានបញ្ចប់

គណៈកម្មការគ្រប់គ្រងបានរៀបចំនូវជំហានចុងក្រោយ ដែលមានរយៈពេល ២ថ្ងៃពេញ នៅក្នុងសប្តាហ៍ទី៤ នៃខែកញ្ញា ឆ្នាំ២០០៨ ដើម្បីធ្វើការសិក្សាយ៉ាងហ្មត់ចត់ទៅលើគម្រោងទិន្នន័យ, ការសន្និដ្ឋាន និង រាល់អនុសាសន៍ទាំងឡាយ ដែលបានលើកឡើងដោយសមាជិកវាយតម្លៃជារួម ជាពិសេសចំណុចដែលបានរកឃើញពិតប្រាកដក្នុងការវិភាគលើ SWOT និងបានបង្ហាញពីភាពសមស្របដែលអាចទទួលយកបាន ។ នៅចុងបញ្ចប់ សមាជិកទាំងអស់បានសម្រេចជាឯកច្ឆ័ន្ទ ដោយបានរក្សាទុកផែនការយុទ្ធសាស្ត្រនេះនៅដដែល ព្រមទាំងបានស្នើឲ្យអង្គការ OEC បន្តខិតខំស្វះស្វែងរកថវិកាបន្ថែម អនុលោមតាមខ្លឹមសារអនុសាសន៍ ក៏ដូចជាស្ថានការណ៍បច្ចុប្បន្ននេះផងដែរ ។

ថ្ងៃសុក្រ ៤រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
បាត់ដំបង, ថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០១៨
ប្រធានគណៈកម្មការគ្រប់គ្រង

ឈឿង ឈុន

**ឧបសម្ព័ន្ធ:**
- ឧបសម្ព័ន្ធ ១
- ឧបសម្ព័ន្ធ ២
- ឧបសម្ព័ន្ធ ៦

បានពិភាគ និង គោរពជូន
លោកជំទាវ ប្រធានក្រុមប្រឹក្សានាយក
« ដើម្បីពិនិត្យ និង អនុម័ត»
បាត់ដំបង, ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨
នាយិកាប្រតិបត្តិ

O.E.C
Operations Enfants du Cambodia

និត_ដាវី

**បានឃើញ និង អនុម័ត**
ប្រធានក្រុមប្រឹក្សានាយក

**ញ៉ឹក សាគន្ធ**